# អំណាចនៃគម្ពីរ

*ដោយអែលឌើរ រីឆាដ ជី ស្កុត*
*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

ព្រះវរបិតានៅស្ថានសួគ៌របស់យើងជ្រាបថា ដើម្បីធ្វើឲ្យយើងមានការរីកចម្រើនដែលប្រកបដោយបំណងប្រាថ្នា ក្នុងអំឡុងពេលសាកល្បងនៃជីវិតរមែងស្លាប់របស់យើងនេះ យើងចាំបាច់ត្រូវប្រឈមមុខនឹងឧបសគ្គលំបាកៗជាច្រើន ។ ឧបសគ្គទាំងនោះមួយចំនួន ស្ទើរតែពុំអាចទ្រាំទ្របាន ។ ទ្រង់បានប្រទានឧបករណ៍ដើម្បីជួយយើងឲ្យទទួលជោគជ័យនៅក្នុងការសាកល្បងនៃជីវិតរមែងស្លាប់របស់យើង ។ ព្រះគម្ពីរគឺជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ទាំងនោះ ។

នៅគ្រប់ជំនាន់ ព្រះវរបិតានៅស្ថានសួគ៌ បានបំផុសគំនិតដល់បុរស និងស្ត្រីជម្រើស ឲ្យស្វែងរកដំណោះស្រាយចំពោះបញ្ហាលំបាកបំផុតនៃជីវិតតាមរយៈការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ ។ ទ្រង់បានបំផុសគំនិតដល់អ្នកបម្រើដែលមានសិទ្ធិអំណាចទាំងឡាយ ឲ្យកត់ត្រាដំណោះស្រាយទាំងនោះ ជាប្រភេទក្បួនខ្នាតសម្រាប់កូនចៅទាំងឡាយរបស់ទ្រង់ដែលមានជំនឿ ទៅលើផែនការនៃសុភមង្គលរបស់ទ្រង់ និងលើព្រះរាជបុត្រាសំណព្វរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ។ យើងអាចទទួលយកការណែនាំនេះគ្រប់ពេល តាមរយៈទ្រព្យសម្បត្តិដែលយើងហៅថា ព្រះគម្ពីរបទដ្ឋាន --- រួមមាន ព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី ព្រះគម្ពីរមរមន គោលលទ្ធិ និងសេចក្ដីសញ្ញា និងមុក្តាដ៏មានតម្លៃមហិមា ។

ដោយសារបទគម្ពីរបានសរសេរឡើងមកពីទំនាក់ទំនងដ៏បំផុសគំនិត តាមរយៈព្រះវិញ្ញាណបរិសុទ្ធ នោះបទគម្ពីរជាសេចក្ដីពិតដ៏បរិសុទ្ធ ។ យើងពុំចាំបាច់ខ្វល់អំពីសុពលភាពនៃគំនិតដែលមាននៅក្នុងព្រះគម្ពីរបទដ្ឋាននោះទេ ដោយព្រោះព្រះវិញ្ញាណបរិសុទ្ធគឺជាអ្នកដឹកនាំដែលមានការលើកទឹកចិត្ត និងបំផុសគំនិតដល់បុគ្គលទាំងឡាយដែលបានសរសេរព្រះគម្ពីរទាំងនេះ ។ ព្រះគម្ពីរគឺដូចជាកញ្ចប់នៃពន្លឺដែលបំភ្លឺគំនិតរបស់យើង ហើយរៀបចំយើងសម្រាប់ការណែនាំ និងការបំផុសគំនិតមកពីស្ថានខ្ពស់ ។

ព្រះគម្ពីរអាចក្លាយទៅជាសោរដើម្បីបើកបណ្ដាញខ្សែនៃទំនាក់ទំនងជាមួយនឹងព្រះវរបិតាដែលគង់នៅស្ថានសួគ៌ និងព្រះរាជបុត្រាសំណព្វរបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទរបស់យើង ។ ព្រះគម្ពីរផ្ដល់ជាកម្លាំងនៃសិទ្ធិអំណាចដល់ការប្រកាសរបស់យើង នៅពេលយើងប្រើប្រាស់ព្រះគម្ពីរទាំងនេះដោយត្រឹមត្រូវ ។ ព្រះគម្ពីរអាចក្លាយជាមិត្តភក្ដិពិតប្រាកដម្នាក់ដែលអាចជួបបាននៅគ្រប់ពេល និងគ្រប់ទីកន្លែង ។ ព្រះគម្ពីរតែងតែរង់ចាំយើងជានិច្ចនៅពេលយើងត្រូវការ ។ ការប្រើប្រាស់ព្រះគម្ពីរផ្ដល់ឲ្យនូវគ្រឹះនៃសេចក្ដីពិតដែលអាចអំពាវនាវដោយព្រះវិញ្ញាណបរិសុទ្ធ ។ ការរៀន ការពិចារណា និងការស្វែងយល់ ហើយនិងការទន្ទេញបទគម្ពីរគឺដូចជាការចាក់បំពេញទូរនូវមិត្តភក្ដិ គុណតម្លៃ និងសេចក្ដីពិត ដែលអាចជួបបាននៅគ្រប់ពេល គ្រប់ទីកន្លែងក្នុងពិភពលោកនេះ ។

អំណាចដ៏អស្ចារ្យអាចទទួលបានមកពីការទន្ទេញបទគម្ពីរទាំងឡាយ ។ ការទន្ទេញបទគម្ពីរគឺដូចជាការបង្កើតមិត្តភក្ដិថ្មីម្នាក់យ៉ាងដូច្នោះដែរ ។ វាគឺដូចជាការស្វែងរកបុគ្គលថ្មីម្នាក់ ដែលអាចជួយនៅក្នុងគ្រាលំបាក ផ្ដល់ការបំផុសគំនិត និងការលួងលោម និងធ្វើជាប្រភពនៃការលើកទឹកចិត្តសម្រាប់ពេលដែលត្រូវការផ្លាស់ប្ដូរ ។ ឧទាហរណ៍ ការប្ដេជ្ញាចិត្តដើម្បីទន្ទេញទំនុកដំកើងនេះ ចំពោះខ្ញុំគឺជាប្រភពនៃអំណាច និងការយល់ដឹង ៖

« ផែនដី និងសារពើនៅលើផែនដីជារបស់ផងព្រះយេហូវ៉ា ព្រមទាំងលោកិយ និងបណ្ដាអ្នកដែលនៅលោកិយផង ។ ត្បិតទ្រង់បានប្រតិស្ឋានផែនដីនៅលើសមុទ្រ ហើយបានតាំងឲ្យមាំមួននៅលើទឹកទាំងពួង ។ ហើយអ្នកណានឹងឡើងទៅឯភ្នំនៃព្រះយេហូវ៉ា តើអ្នកនឹងឈរនៅក្នុងទីបរិសុទ្ធរបស់ទ្រង់បាន ? តើអ្នកដែលមានដៃស្អាត និងចិត្តបរិសុទ្ធជាអ្នកដែលមិនបណ្ដោយឲ្យព្រលឹងខ្លួនទៅតាមសេចក្ដីភូតភរ ហើយមិនបានស្បថប្រវ័ញ្ចគេឡើយ ។ អ្នកនោះនឹងទទួលពរពីព្រះយេហូវ៉ា ហើយនឹងសេចក្ដីសុចរិតពីព្រះដ៏ជួយសង្គ្រោះខ្លួន » ( ទំនុកដំកើង 24:1--5 ) ។

ការសញ្ជឹងគិតពីបទគម្ពីរមួយតាមបែបនោះផ្ដល់ឲ្យនូវទិសដៅដ៏អស្ចារ្យចំពោះជីវិត ។ បទគម្ពីរអាចជាគ្រឹះមួយដើម្បីគាំទ្រ ។ បទគម្ពីរអាចផ្ដល់ឲ្យនូវធនធានដ៏វិសេសអស្ចារ្យនៃមិត្តភក្ដិដែលស្ម័គ្រចិត្តចង់ជួយយើង ។ បទគម្ពីរដែលបានទន្ទេញចាំក្លាយទៅជាមិត្តភក្ដិរឹងមាំម្នាក់ដែលមិនចេះទន់ជ្រាយតាមពេលវេលាឡើយ ។

ការសញ្ជឹងគិតពីរបៀបមួយនៃបទគម្ពីរអាចក្លាយទៅជាកូនសោដើម្បីចាក់យកវិវរណៈ និងសេចក្ដីណែនាំ និងការបំផុសគំនិតមកពីព្រះវិញ្ញាណបរិសុទ្ធ ។ បទគម្ពីរអាចបន្ទន់ដល់ដួងចិត្តសោកសៅមួយ ផ្ដល់សេចក្ដីសុខសាន្ត សេចក្ដីសង្ឃឹម និងស្ដារទំនុកចិត្តទៅលើសមត្ថភាពរបស់មនុស្សម្នាក់ដើម្បីយកឈ្នះឧបសគ្គទាំងឡាយនៅក្នុងជីវិត ។ បទគម្ពីរមាននូវអំណាចដ៏អស្ចារ្យដើម្បីព្យាបាលការលំបាកខាងសតិអារម្មណ៍ នៅពេលមានសេចក្ដីជំនឿលើព្រះអង្គសង្គ្រោះ ។ បទគម្ពីរអាចព្យាបាលរូបកាយបានយ៉ាងឆាប់រហ័សបំផុត ។

បទគម្ពីរអាចមានទំនាក់ទំនងតាមវិធីខុសៗគ្នា ក្នុងពេលវេលាផ្សេងគ្នា ស្របតាមសេចក្ដីត្រូវការរបស់យើង ។ បទគម្ពីរមួយដែលយើងអានជាច្រើនដង អាចមានន័យផ្សេងដោយផ្ដល់ជាគំនិតថ្មី នៅពេលយើងជួបនឹងបញ្ហាថ្មីនៅក្នុងជីវិត ។ តើអ្នកប្រើប្រាស់បទគម្ពីរផ្ទាល់ខ្លួនយ៉ាងដូចម្ដេច ? តើអ្នកបានគូសចំណាំបទគម្ពីររបស់អ្នកដែរឬទេ ? តើអ្នកបានសរសេរសំគាល់នៅរឹមទំព័រទុកដើម្បីចងចាំពីការណែនាំខាងវិញ្ញាណ ឬបទពិសោធន៍ដែលបង្រៀននូវមេរៀនដ៏ស៊ីជំរៅដែរឬទេ ? តើអ្នកមានបានប្រើប្រាស់ព្រះគម្ពីរបទដ្ឋានទាំងអស់ រួមទាំង ព្រះគម្ពីរសញ្ញាចាស់ដែរឬទេ ? ខ្ញុំបានរកឃើញសេចក្ដីពិតដ៏មានតម្លៃនៅក្នុងទំព័រនៃព្រះគម្ពីរសញ្ញាចាស់ ដែលជាផ្នែកដ៏សំខាន់ចំពោះមូលដ្ឋាននៃសេចក្ដីពិតដែលដឹកនាំជីវិតរបស់ខ្ញុំ និងដើរតួជាធនធានមួយ នៅពេលខ្ញុំព្យាយាមចែកចាយសារលិខិតដំណឹងល្អជាមួយនឹងអ្នកដទៃទៀត ។ ដោយសារហេតុនោះហើយ ធ្វើឲ្យខ្ញុំស្រឡាញ់ព្រះគម្ពីរសញ្ញាចាស់ ។ ខ្ញុំរកឃើញត្បូងដ៏មានតម្លៃនៃសេចក្ដីពិតនៅលើគ្រប់ទំព័រនៃព្រះគម្ពីរសញ្ញាចាស់ ។ ឧទាហរណ៍ ៖

« សាំយ៉ូអែលទូលឆ្លើយថា តើព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យនឹង  ដង្វាយដុត ហើយនឹងយញ្ញបូជា ឲ្យស្មើនឹងការស្ដាប់តាមទ្រង់ឬអី មើលដែលស្ដាប់បង្គាប់ នោះវិសេសលើសជាងយញ្ញបូជា ហើយដែលផ្ទៀងត្រចៀក នោះក៏វិសេសជាងខ្លាញ់នៃចៀមឈ្មោលទៅទៀត »
(សាំយ៉ូអែលទី1 15:22 ) ។

« ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ ។ ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ នោះទ្រង់នឹងដំរង់អស់ទាំងផ្លូវច្រករបស់ឯង ។ កុំឲ្យមើលខ្លួនថាមានប្រាជ្ញាឡើយ ចូរកោតខ្លាចដល់ព្រះយេហូវ៉ាវិញ ហើយចៀសចេញពីសេចក្ដីអាក្រក់ទៅ... ។

« កូនអើយ កុំឲ្យមើលងាយសេចក្ដីប្រៀនរបស់ព្រះយេហូវ៉ាឡើយ ក៏កុំឲ្យណាយចិត្តនឹងសេចក្ដីបន្ទោសរបស់ទ្រង់ដែរ ។ ត្បិតអ្នកណាដែលព្រះយេហូវ៉ាទ្រង់ស្រឡាញ់ នោះទ្រង់ក៏ស្ដីប្រដៅផង គឺដូចជាឪពុកធ្វើចំពោះកូនដែលជាទីគាប់ចិត្តដល់ខ្លួនដែរ ។ សប្បាយហើយ អស់អ្នកណាដែលរកបានប្រាជ្ញា ហើយអ្នកណាដែលខំប្រឹងទាល់តែបានយោបល់ » ( សុភាសិត 3:5--7, 11--13 ) ។

ព្រះគម្ពីរសញ្ញាថ្មីក៏ជាប្រភពមួយនៃសេចក្ដីពិតដ៏មានតម្លៃផងដែរ ៖ « នោះព្រះយេស៊ូវឆ្លើយថា ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង ។ នេះជាបញ្ញត្តិយ៉ាងសំខាន់ទីមួយ ។ ហើយបញ្ញត្តិទីពីរក៏បែបដូចគ្នា គឺថា ត្រូវស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង ។ បណ្ដាក្រឹត្យវិន័យ និងអស់ទាំងទំនាយហោរាទាំងប៉ុន្មាន ក៏សម្រេចនៅបទបញ្ញត្តិទាំងពីរប្រការនេះឯង » ( ម៉ាថាយ 22:37--40 ) ។

« ព្រះអម្ចាស់ក៏មានបន្ទូលថា ស៊ីម៉ូនៗអើយ មើលសាតាំងបានសូមចង់បានអ្នករាល់គ្នា ប្រយោជន៍នឹងរែងអ្នករាល់គ្នា ដូចជារែងអង្ករ ៖ ប៉ុន្តែ ខ្ញុំបានអធិស្ឋានឲ្យអ្នក ដើម្បីមិនឲ្យសេចក្ដីជំនឿរបស់អ្នកវិនាសបាត់ឡើយ កាលណាអ្នកបានប្រែចិត្តវិលមកវិញ នោះចូរចម្រើនឲ្យបងប្អូនអ្នកបានខ្ជាប់ខ្ជួនឡើង ។ តែគាត់ទូលទ្រង់ថាព្រះអម្ចាស់អើយទូលបង្គំប្រុងប្រៀបជាស្រេចនឹងទៅជាមួយនឹងទ្រង់ដែរ ទោះបើជាប់គុក ឬដល់ស្លាប់ក្ដី ។ នោះទ្រង់មានបន្ទូលថា ពេត្រុសអើយ ខ្ញុំប្រាប់អ្នកថា នៅថ្ងៃនេះមាន់មិនរងាវឡើយ ទាល់តែអ្នកបានប្រកែកបីដងថា មិនស្គាល់ខ្ញុំ ។

« មានស្រីបម្រើម្នាក់ឃើញគាត់អង្គុយនៅជិតភ្លើង ក៏សម្លឹងមើល ហើយនិយាយថា អ្នកនេះបាននៅជាមួយនឹងមនុស្សនោះដែរ ។ តែគាត់ប្រកែកថា នាងអើយ ខ្ញុំមិនស្គាល់មនុស្សនោះទេ ។ ក្រោយបន្តិចមក មានម្នាក់ទៀតឃើញគាត់ ហើយក៏ថា អ្នកឯងជាពួកនោះដែរ តែពេត្រុសឆ្លើយថា អ្នកអើយខ្ញុំមិនមែនទេ ។

« រួចប្រហែលជាមួយម៉ោងក្រោយមក មានម្នាក់ទៀតថា អ្នកនេះប្រាកដជាបាននៅជាមួយនឹងមនុស្សនោះដែរ ត្បិតជាសាសន៍កាលីឡេដូចគ្នា ។ តែពេត្រុសប្រកែកថា អ្នកអើយ ខ្ញុំមិនដឹងជាអ្នកថាដូចម្ដេចទេ កាលគាត់កំពុងតែនិយាយនៅឡើយ នោះស្រាប់តែមាន់រងាវឡើង ។

« ហើយព្រះអម្ចាស់ទ្រង់បែរមកទតមើលពេត្រុស នោះពេត្រុសក៏នឹកឃើញពីព្រះបន្ទូលនៃព្រះអម្ចាស់ ដែលមានបន្ទូលនឹងគាត់ថា មុនដែលមាន់រងាវ នោះអ្នកនឹងប្រកែកបីដងថា មិនស្គាល់ខ្ញុំ ។ រួចគាត់ចេញទៅក្រៅដោយយំក្ដួល » ( លូកា 22:31--34, 56--62 ) ។

បទគម្ពីរដែលដកស្រង់ចេញពីគោលលទ្ធិ និងសេចក្ដីសញ្ញានេះបានផ្ដល់ពរជ័យយ៉ាងច្រើនដល់ជីវិតខ្ញុំ ៖ « ចូរកុំខំប្រកាសព្រះបន្ទូលរបស់យើងឡើយ ប៉ុន្តែចូរខំព្យាយាម ដើម្បីឲ្យបានព្រះបន្ទូលរបស់យើងជាមុនសិនចុះ ហើយខណៈនោះ អណ្ដាតរបស់អ្នកនឹងបានធូរ ពេលនោះ បើសិនជាអ្នកមានប្រាជ្ញា នោះអ្នកនឹងបានព្រះវិញ្ញាណរបស់យើង និងព្រះបន្ទូលរបស់យើង មែនហើយ គឺជាព្រះចេស្ដានៃព្រះ ដើម្បីបញ្ចុះបញ្ចូលមនុស្សលោក »
( គ. និង ស. 11:21 ) ។

តាមទស្សនៈរបស់ខ្ញុំ ព្រះគម្ពីរមរមនបង្រៀនសេចក្ដីពិត ដោយមានភាពច្បាស់លាស់ និងអំណាចយ៉ាងពិសេស ។ ឧទាហរណ៍ ៖

« ហើយឥឡូវនេះ ខ្ញុំចង់ឲ្យអ្នករាល់គ្នាបន្ទាបខ្លួន ហើយចុះចូល ហើយសុភាពទន់ភ្លន់ រហ័សធ្វើតាមការណ៍ល្អ ពោរពេញទៅដោយការទ្រាំទ្រ និងការអត់ធ្មត់ សង្កត់ចិត្តក្នុងកិច្ចការគ្រប់យ៉ាង មានចិត្តព្យាយាមក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ឲ្យបានគ្រប់ពេលវេលា សូមនូវអ្វីដែលអ្នកត្រូវការ ទាំងខាងឯវិញ្ញាណ និងខាងឯសាច់ឈាមដែរ ថ្លែងអំណរគុណដល់ព្រះជានិច្ច ចំពោះអ្វីដែលអ្នកបានទទួល ។

« ហើយចូរឲ្យឃើញថា អ្នករាល់គ្នាមានសេចក្ដីជំនឿ សេចក្ដីសង្ឃឹម និងសេចក្ដីសប្បុរស ហើយនៅពេលនោះអ្នករាល់គ្នានឹងបានបរិបូរណ៍ទៅដោយកិច្ចការល្អៗជានិច្ច » ( អាលម៉ា 7:23--24 ) ។

ហើយមួយទៀតគឺ ៖ « ហើយសេចក្ដីសប្បុរសតែងតែអត់ធ្មត់ ហើយចិត្តល្អ ហើយពុំចេះឈ្នានីស ហើយពុំចេះអួតខ្លួន ពុំរកប្រយោជន៍ផ្ទាល់ខ្លួន ពុំរហ័សខឹង ពុំគិតដល់សេចក្ដីអាក្រក់ ហើយពុំដែលអររីករាយចំពោះ សេចក្ដីសុចរិតឡើយ ប៉ុន្តែអររីករាយតែនឹងសេចក្ដីពិតវិញ គឺទ្រាំទ្រការណ៍ទាំងអស់ សង្ឃឹមដល់ការណ៍ទាំងអស់ ហើយស៊ូទ្រាំទ្រការណ៍ទាំងអស់ ។

« ហេតុដូច្នោះហើយ ឱបងប្អូនជាទីស្រឡាញ់របស់ខ្ញុំអើយ បើសិនជាអ្នករាល់គ្នាគ្មាន សេចក្ដីសប្បុរសទេ នោះអ្នករាល់គ្នាគ្មានជាអ្វីទាំងអស់ ត្បិតសេចក្ដីសប្បុរសពុំបាត់បង់ទៅឡើយ ។ ហេតុដូច្នោះហើយ ចូរតោងជាប់សេចក្ដីសប្បុរស ដែលជាសេចក្ដីដ៏មហិមាបំផុត ត្បិតអ្វីផ្សេងៗទៀតនឹងត្រូវខូចបង់--- ប៉ុន្តែសេចក្ដីសប្បុរស គឺជាសេចក្ដីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ ហើយស្ថិតស្ថេរនៅជានិច្ច ហើយអស់អ្នកណាដែលមានចិត្តសប្បុរស នៅក្នុងថ្ងៃចុងក្រោយបង្អស់នឹងបានស្រួលដល់អ្នកនោះវិញ ។

« ហេតុដូច្នោះហើយ ឱបងប្អូនដ៏ជាទីស្រឡាញ់របស់ខ្ញុំអើយ ចូរអធិស្ឋានដល់ព្រះវរបិតាដោយអស់ពីកម្លាំងចិត្ត ដើម្បីឲ្យអ្នករាល់គ្នាបានពោរពេញដោយសេចក្ដីស្រឡាញ់នេះ ដែលទ្រង់បានប្រទានដល់អស់អ្នកណាដែលជាអ្នកដើរតាមដ៏ពិត នៃព្រះរាជបុត្រារបស់ទ្រង់គឺព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យអ្នករាល់គ្នាក្លាយទៅជាកូនព្រះ ដើម្បី កាលណាទ្រង់នឹងលេចមក នោះយើងរាល់គ្នានឹងបានដូចជាទ្រង់ ត្បិតយើងនឹងឃើញទ្រង់ជាទ្រង់ពិតប្រាកដ ដើម្បី ឲ្យយើងអាចមានសេចក្ដីសង្ឃឹមនេះ ដើម្បីឲ្យយើងអាចបានបរិសុទ្ធដូចជា ទ្រង់បរិសុទ្ធ » ( មរ៉ូណៃ 7:45--48 ) ។

ជីនីន ភរិយាដ៏មានតម្លៃរបស់ខ្ញុំស្រឡាញ់ព្រះគម្ពីរមរមន ។ កាលពីគាត់នៅក្មេង ព្រះគម្ពីរមរមនបានក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ជីវិតគាត់ ។ វាគឺជាប្រភពមួយនៃការបង្រៀន និងទីបន្ទាល់ នៅអំឡុងពេលបម្រើបេស-កកម្មពេញម៉ោងរបស់គាត់ នៅអាមេរិកភាគខាងជើង ។ នៅពេលយើងបម្រើបេសកកម្មនៅតំបន់គ័រដូបា ប្រទេសអាហ្សង់ទីន គាត់បានលើកទឹកចិត្តយ៉ាងខ្លាំងឲ្យមានការប្រើប្រាស់ព្រះគម្ពីរមរមនក្នុងការផ្សាយសាសនា ។ ជីនីនបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងជីវិតរបស់គាត់តាំងពីមុនថា អស់អ្នកទាំងឡាយណាដែលអានព្រះគម្ពីរមរមនឲ្យបានជាប់លាប់ គឺត្រូវបានប្រទានពរដែលមិនអាចវាស់បាន ជាព្រះវិញ្ញាណនៃព្រះអម្ចាស់ ជាការប្ដេជ្ញាចិត្តដ៏អស្ចារ្យ ដើម្បីគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ហើយមានទីបន្ទាល់កាន់តែរឹងមាំអំពីទេវភាពនៃព្រះរាជបុត្រានៃព្រះ ។[1] ជាច្រើនឆ្នាំមកហើយ ខ្ញុំមិនដឹងថាប៉ុន្មានដងទេ រាល់ពេលចុងឆ្នាំ ខ្ញុំនឹងឃើញគាត់អង្គុយដោយស្ងៀមស្ងាត់ អានព្រះគម្ពីរមរមនឲ្យចប់ម្ដងទៀតមុនពេលដាច់ឆ្នាំ ។

នៅឆ្នាំ 1991 ក្នុងឱកាសបុណ្យគ្រីស្ទម៉ាស់ ខ្ញុំចង់ឲ្យអំណោយពិសេសមួយដល់ក្រុមគ្រួសារខ្ញុំ ។ ដើម្បីបំពេញប្រាថ្នានោះ ខ្ញុំបានសរសេរនៅក្នុងសៀវភៅកំណត់ហេតុរបស់ខ្ញុំថា ៖ « ឥឡូវនេះម៉ោង 12:38 យប់ ថ្ងៃពុធ ទី 18 ខែ ធ្នូ ឆ្នាំ 1991 ។ ខ្ញុំទើបបានបញ្ចប់ការអាត់ខ្សែសម្លេងពីព្រះគម្ពីរមរមនសម្រាប់ក្រុមគ្រួសារខ្ញុំ ។ ការណ៍នេះបានក្លាយទៅជាបទពិសោធន៍មួយដែលបង្កើនទីបន្ទាល់របស់ខ្ញុំអំពីកិច្ចការដ៏ទេវភាពនេះ ហើយពង្រឹងបំណងប្រាថ្នាក្នុងខ្លួនខ្ញុំ ដើម្បីចង់ចេះចង់ដឹងបន្ថែមទៀតពីព្រះគម្ពីរមរមន ដើម្បីរៀនពីបទគម្ពីរនៃសេចក្ដីពិតទាំងនេះ ដើម្បីប្រើប្រាស់នៅក្នុងការបម្រើរបស់ខ្ញុំចំពោះព្រះអម្ចាស់ ។ ខ្ញុំស្រឡាញ់ព្រះគម្ពីរនេះណាស់ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ដោយអស់ពីដួងចិត្តខ្ញុំថា វាគឺជាការពិត ហើយថាព្រះគម្ពីរមរមនគឺត្រូវបានរៀបចំសម្រាប់ពរជ័យនៃវង្សអ៊ីស្រាអ៊ែល និងវង្សអ៊ីស្រាអ៊ែលនៅផ្នែកផ្សេងៗទៀត ដែលបានបែកខ្ញែកគ្នានៅទូទាំងពិភពលោក ។ អស់អ្នកទាំងឡាយណាដែលនឹងសិក្សាពីសារលិខិតនេះ ដោយសុភាពរាបសា ដោយមានជំនឿជឿលើព្រះយេស៊ូវគ្រីស្ទ នឹងស្គាល់ពីសេចក្ដីពិតពេញលេញរបស់ព្រះគម្ពីរនេះ ហើយនឹងរកឃើញរតនៈសម្បត្តិដែលនាំទៅរកសុភមង្គល សេចក្ដីសុខសាន្ត និងការសម្រេចបានដ៏មហិមានៅក្នុងជីវិតនេះ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ក្នុងរបៀបដ៏ពិសិដ្ឋបំផុតថា ព្រះគម្ពីរនេះគឺជាព្រះគម្ពីរពិត » ។

សូមឲ្យយើងម្នាក់ៗចេះប្រើប្រាស់នូវទ្រព្យសម្បត្តិនៃពរជ័យដ៏មហិមាដែលជាលទ្ធផលមកពីការសិក្សាព្រះគម្ពីរ ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល Gordon B. Hinckley « A Testimony Vibrant and True » Liahona និង Ensign ខែ សីហា ឆ្នាំ 2005 ទំព័រ 6 ។